ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៥១៦ "ឯ" ក្រ.ព
-ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៩០
ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨
-សំណុំរឿងស៊ើបសួរលេខ ៣៧១២
ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨
-សំណុំរឿងជំនុំជម្រះលេខ ៩៥
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការទី១ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧៩០ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១/ឈ្មោះ [redacted] **ជារិទ្ធ** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងផ្សារដែក ទីកន្លែងកំណើ [redacted] រាជធានីភ្នំពេញ ទីលំនៅសព្វថ្ងៃស្នាក់នៅផ្ទះមិនចាំលេខ ផ្លូវលំ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] **កុសល** "រស់" ម្តាយឈ្មោះ [redacted] **ចាន់ទិ** "រស់" ទោសពីមុនគ្មាន ជាអនីតិជន ។ (ឃាត់ខ្លួន)

-ដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្នលេខ ៩១០៥ "ឧ" ដ.ឃ.ដ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

២/ឈ្ម [redacted] **សក្ករ៉ែត** ភេទប្រុស អាយុ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើ [redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ១៩៩៥ ផ្លូវលំ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ [redacted] **ប៊ុនហុង** "រស់" ម្តាយឈ្មោះ [redacted] **គីម** "រស់" ទោសពីមុនគ្មាន ជានីតិជន ។ (ឃាត់ខ្លួន)

-ដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្នលេខ ៩២៩០ "ឧ" ដ.ឃ.ដ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ជាប់ចោទពីបទ: **លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវពាក្យ៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង១៩ និង៣០នាទី នៅចំណុចផ្ទះគ្មានលេខ ផ្លូវលេខ៣៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណីឆក់ទូរស័ព្ទដៃ ពីមនុស្សម្នាក់មិនស្គាល់អត្តសញ្ញាណ ជនជាតិចិន កំពុងដើរមានគ្នា០២នាក់ ដៃកាន់ទូរស័ព្ទ ហើយជនសង្ស័យចំនួនពីរនាក់ជិះម៉ូតូមួយគ្រឿងម៉ាក ស៊ុយហ្សូគីនិចពណ៌ស ស៊េរីឆ្នាំ២០១៥ ពាក់ស្លាក់លេខភ្នំពេញ ១FG-៧១៨១ ដោយឈ្មោះ [redacted] ដារិទ្ធ ជិះម៉ូតូឌុបឈ្មោះ [redacted] សក្ករ៉ែត ហៅ ហ្សាន លុះជិះមកដល់ចំណុចកើតហេតុឈ្មោះ ណេត ដារិទ្ធ ក៏បានបើកម៉ូតូទៅជិតជនរងគ្រោះដែលកំពុងដើរហើយឈ្មោះ [redacted]សក្ករ៉ែត ហៅ ហ្សាន ដែលអង្គុយពីក្រោយក៏ធ្វើសកម្មភាពឆក់យកទូរស័ព្ទដៃពីជនរងគ្រោះតែមិនបានសម្រេចក៏បើកម៉ូតូគេចខ្លួនបាត់តែម្តង ។

-បានឃើញ របាយការណ៍សំយោគលេខ ៣១៦/១៨ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣៥១០ អ.ឃ.ជ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ០៤៨ អ.ឃ.ញ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៩៦ "ឧ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

ឆាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ បានឆ្លើយថា៖ ខ្ញុំពិតជាបានប្រព្រឹត្តមែន ខ្ញុំកើត១១.១១.២០១១ កាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៩ និង៣០នាទី ខ្លួននិងបក្ខពួកឈ្មោះ [redacted]សក្ករ៉ែត ពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនជាតិចិន តែមិនបានសម្រេចពិតប្រាកដមែន ដោយខ្លួននិងបក្ខពួកជិះម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ ១FG-៧១៨១ ជាម៉ូតូរបស់ខ្លួនធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីមនុស្សជនជាតិចិនកំពុងដើរកាន់ទូរស័ព្ទដៃមានគ្នាពីរនាក់ នៅចំណុចខាងលិចផ្សារបឹងកេងកង សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយខ្លួនក៏បានជិះម៉ូតូទៅជិតជនរងគ្រោះ ហើយឈ្មោះ [redacted]សក្ករ៉ែត ជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនជាតិចិននោះតែមិនបានសម្រេច ហើយខ្លួន និងបក្ខពួកក៏ជិះម៉ូតូគេចខ្លួន រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៦ និង០០ នាទី ខ្លួននិងឈ្មោះ [redacted] សក្ករ៉ែត ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួននៅចំណុចក្នុងមជ្ឈមណ្ឌលកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted]សក្ករ៉ែត បានឆ្លើយថា៖ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៩ និង៣០នាទី ខ្លួននិងបក្ខពួកឈ្មោះ ណេត ដារិទ្ធ ពិតជាបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនជាតិចិនតែមិនបានសម្រេចពិតប្រាកដមែន ដោយខ្លួននិងឈ្មោះ [redacted]ដារិទ្ធ បានជិះម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ ១FG-៧១៨១ ជាម៉ូតូរបស់ឈ្មោះ [redacted]ដារិទ្ធ ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីមនុស្សប្រុសជនជាតិចិនកំពុងដើរកាន់ទូរស័ព្ទមានគ្នាពីរនាក់ នៅចំណុចខាងលិចផ្សារបឹងកេងកង សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយឈ្មោះ [redacted] ដារិទ្ធ បានជិះម៉ូតូទៅជិតជនរងគ្រោះហើយខ្លួនជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនជាតិចិននោះតែមិនបានសម្រេច ហើយខ្លួន និងឈ្មោះ [redacted]ដារិទ្ធ ក៏ជិះម៉ូតូគេចខ្លួន។ រហូតដល់ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៦ និង៥០នាទី ខ្លួននិងឈ្មោះ [redacted]ដារិទ្ធ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនចំណុចក្នុងមជ្ឈមណ្ឌលកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

- អំណាងរបាយការណ៍លេខ ៣១៦/១៨ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌ កំរិតស្រាល បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តវ៉ែត ភេទប្រុស អាយុ ១៨ឆ្នាំ ពិតជាបានប្រព្រឹត្ត **ឆក់ទូរស័ព្ទដៃ** របស់ជនរងគ្រោះជាជនជាតិចិន ពិតប្រាកដមែន ។

សេចក្តីសន្និដ្ឋានឆ្លើយសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការរួចមក ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តវ៉ែត ភេទប្រុស អាយុ១៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **ល្មួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ដែលឈ្មើសនឹងមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ដោយតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ: ០៤៨ អ.យ.ញ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ ទុកនៅដដែល។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីខ្ញុំបានឆ្លើយសារភាពនូវអំពើដែលធ្វើឡើងដោយខ្វះការពិចារណា ស្នើសុំឲ្យផ្តល់ស្ថានសម្រាលតាមមាត្រា ១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សក្តវ៉ែត បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីខ្ញុំបានឆ្លើយសារភាពអំពើដែលធ្វើឡើងដោយខ្វះការពិចារណា ស្នើសុំឲ្យផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនផង។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្ញុំសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្ញុំផង ។

-ជនជាប់ចោទឈ្មោះ [redacted] សក្តវ៉ែត បាននិយាយសំដីចុងក្រោយបង្អស់ថា៖ ខ្ញុំសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ខ្ញុំផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ៩៦ "ឧ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ ឃើញថា កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ១៩ និង ៣០នាទី នៅចំណុចផ្ទះគ្មានលេខ ផ្លូវពា៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ពិតជាមានករណី **ល្មួចមានស្ថានទម្ងន់ទោស** មួយបានកើតឡើងដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តវ៉ែត ភេទប្រុស អាយុ១៨ឆ្នាំ ប្រាកដមែន។

២-ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តអ៊ត ភេទប្រុស អាយុ១៨ឆ្នាំ ថាខ្លួនពិតជាបានប្រព្រឹត្តអំពើ **លួចមានស្តានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ១៩ និង ៣០នាទី នៅចំណុចផ្ទះគ្មានលេខ ផ្លូវ៣៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែន។

៣-តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ចម្លើយសារភាពរបស់ជនជាប់ចោទ និងការប្តឹងសុំរបស់តំណាងអយ្យការ ព្រមទាំងការពិនិត្យភស្តុតាងជាឯកសារនានា ឃើញថាមានភស្តុតាងស៊ីសង្វាក់ដែលអាចអោយតុលាការជឿជាក់បានដោយគ្មានមន្ទិលថា កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ១៩ និង ៣០នាទី នៅចំណុចផ្ទះគ្មានលេខ ផ្លូវ៣៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ពិតជាមានករណី **លួចមានស្តានទម្ងន់ទោស (ឆក់ទូរស័ព្ទ)** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តអ៊ត ភេទប្រុស អាយុ១៨ឆ្នាំ ប្រាកដមែន។

៤-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ០៤៨ អ.យ.ញ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ទុកដដែល ជាសេចក្តីសន្និដ្ឋានដែលមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ គប្បីតុលាការពិចារណា និងសម្រេចតាមបាន។

៥-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា និងសម្រេច។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសង្គម ររបៀបរៀបរយសាធារណៈ ដែលច្បាប់បានការពារ និងតម្រូវឲ្យផ្តន្ទាទោសតាមច្បាប់។

៧-នៅពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ជាអនីតិជន ដែលមានសមត្ថភាពស្មារតីគ្រប់គ្រាន់ និងយល់ដឹងអំពើរបស់ខ្លួនក្នុងកំរិតខ្លួនជាអនីតិជន គប្បីតុលាការពិចារណាកំរិតការផ្តន្ទាទោសតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ [redacted] សក្តអ៊ត ភេទប្រុស អាយុ១៨ឆ្នាំ ពីបទ: **លួចមានស្តានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេ ផ្លូវ៣៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ៖

១.១/ឈ្មោះ [redacted] ដារិទ្ធ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ។

១.២/ឈ្មោះ [redacted] សក្តអ៊ត ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ ឆ្នាំ ០៦ ខែ (បីឆ្នាំប្រាំមួយខែ) ។

ពីបទ: **លួចមានស្តានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ)** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវ៣៧០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។